“គ្មានការចម្លងមេរោគអេដស៍”

# ឧបករណ៍ជំនួយៈ សម្រាប់អ្នកផ្តល់សេវាសុខភាព និងអ្នកផ្តល់ប្រឹក្សាដែលធ្វើការជាមួយ អ្នករស់នៅជាមួយមេរោគអេដស៍

## តើអ្នកជំងឺត្រូវធ្វើតេស្តរាប់បន្ទុកមេរោគអេដស៍ (Viral Load) នៅពេលណាខ្លះ?



**ការធ្វើតេស្ត Viral Load ជាប្រចាំ** គួរតែធ្វើនៅ**ខែទី ៦ និង ខែទី១២** បន្ទាប់ពីចាប់ផ្តើមប្រើឱសថARVs, និង**រៀងរាល់ ១២ ខែម្តងបន្ទាប់ពីនោះ** ប្រសិនបើលទ្ធផលតេស្តរាប់បន្ទុកមេរោគអេដស៍ក្នុងឈាម **មិនអាចរាប់បាន** (ទាបជាង ៤០ copies/ml) ។

## តើ ចំនួនមេរោគ “មិនអាចរាប់បាន = មិនអាចចម្លងបាន” (ម=ម) មានន័យដូចម្តេច?



**ចំនួនបន្ទុកមេរោគអេដស៍ <៤0 copies/ml** មានន័យថាការព្យាបាលមានប្រសិទ្ធភាព។



សូមបន្តតាមដានធ្វើតេស្តរាប់បន្ទុកមេរោគរបស់អ្នកជំងឺ **ឱ្យបានទៀងទាត់តាមកាលវិភាគ។**



**អ្នកជំងឺមិនអាចឈប់លេបឱសថARVsនោះទេ** ទោះបីជា មេរោគត្រូវបានបង្ក្រាប ឬមិនអាចរាប់បានក៏ដោយ។

**“ម=ម” អាចជួយការពារការចម្លងមេរោគអេដស៍** ទៅដល់ដៃគូរបស់អ្នកផ្ទុកមេរោគអេដស៍ ឬទៅដល់ ទារកក្នុងផ្ទៃ និង ទារក ឬកុមារ កំពុងបំបៅដោះ។



## គំនូសបំព្រួញនៃការតាមដាន Viral Load នៅកម្ពុជា




(សូមអានឯកសារយោងលម្អិតៈ
១). សេចក្តីណែនាំ ស្តីពីការពង្រឹងការលេបថ្នាំត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់តាមរយៈការតាមដាន លទ្ធផលតេស្តរាប់បន្ទុកមេរោគអេដស៍ និងការបង្កើន ប្រសិទ្ធិភាពរបបឱសថដើម្បីលុបបំបាត់បន្ទុកមេរោគអេដស៍ក្នុងឈាម ចំពោះអ្នកជំងឺដែលកំពុងប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍, បោះពុម្ពលើកទី២ ខែ មេសា ឆ្នាំ ២០២០ ។
២). ឧបករណ៍ជំនួយ សម្រាប់អ្នកផ្តល់សេវា សុខភាព និង អ្នកផ្តល់ប្រឹក្សាដែលធ្វើការជាមួយអ្នករស់នៅជាមួយមេរោគអេដស៍។

“គ្មានការចម្លងមេរោគអេដស៍”

# និយមន័យ ម=ម

## ចំនួនមេរោគ “មិនអាចរាប់បាន = មិនអាចចម្លងបាន”





ខ្ញុំមិនចង់ឱ្យកូន និងដៃគូឆ្លងមេរោគអេដស៍ពីខ្ញុំ....

ខ្ញុំមានបញ្ហាផ្សេងៗដែលធ្វើឱ្យខ្ញុំពិបាកនឹងផ្ដោតតែទៅលើសុខភាពរបស់ខ្ញុំ...!!!





ខ្ញុំកំពុងជួបការលំបាកក្នុងការលេបឱសថប្រឆាំងមេរោគអេដស៍....



**កុំបារម្ភ “ម=ម” អាចជួយបាន...!!!**

ខ្ញុំនឹងប្រាប់អ្នកថាតើអ្នកគួរដឹង និងត្រូវធ្វើអ្វីខ្លះ....តោះមកតាមខ្ញុំ៖

**តើអ្វីខ្លះដែលអ្នកគួរដឹង ?**



❶ អ្នកត្រូវមកបូមឈាមរាប់បន្ទុកមេរោគអេដស៍ក្នុងឈាមជាប្រចាំ។ គួរតែធ្វើនៅខែទី ៦ និងខែទី១២ក្រោយពេលអ្នកចាប់ផ្ដើមការព្យាបាល និងរៀងរាល់ ១២ខែម្ដងបន្ទាប់ពីនោះមក។

❷ ប្រសិនបើលទ្ធផលតេស្តរាប់បន្ទុកមេរោគអេដស៍ក្នុងឈាម ក្នុងកម្រិតមួយដែលមិនអាចរាប់បាន (ស្ថិតនៅក្រោម ៤០ copies/ml) អ្នកនឹងមិនអាចចម្លងមេរោគអេដស៍បានទេ។

**តើអ្វីខ្លះដែលអ្នកត្រូវធ្វើ ?**

**ចំនួនមេរោគ “មិនអាចរាប់បាន = មិនអាចចម្លងបាន” (ម=ម)**

**ជួយអ្នកឱ្យមានសុខភាពល្អ និងការពារការចម្លងមេរោគអេដស៍**ទៅដល់ដៃគូរបស់អ្នកឬទៅដល់ទារក និងកុមារដែលកំពុងបំបៅដោះ។



**អ្នកត្រូវតែរក្សាកម្រិតបន្ទុកមេរោគអេដស៍ឱ្យនៅតែមិនអាចរាប់បាន** ដោយបន្តការលេបថ្នាំត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ៗ



**អ្នកត្រូវមកជួបតាមការណាត់របស់គ្រូពេទ្យ**ឱ្យបានជាប់លាប់ និងទៀងទាត់ និង ធ្វើតេស្តរាប់បន្ទុកមេរោគអេដស៍ក្នុងឈាមតាមកាលកំណត់។



**អ្នកមិនត្រូវឈប់លេបឱសថប្រឆាំងមេរោគអេដស៍ទេ** ទោះបីជាមេរោគរបស់អ្នកត្រូវបានបង្ក្រាប ឬមិនអាចរាប់បានក៏ដោយ(*)។

(*) ចំនួនមេរោគអេដស៍មិនអាចរាប់បាន មិនមែនមានន័យថា អ្នកមិនមានមេរោគអេដស៍ក្នុងខ្លួន ឬ អ្នកជាសះស្បើយនោះទេ។



# ដំណើរឆ្ពោះទៅរក បន្ទុកមេរោគអេដស៍ "មិនអាចរាប់បាន"



ឱសថប្រឆាំងមេរោគអេដស៍អាចកាត់បន្ថយចំនួនមេរោគអេដស៍នៅក្នុងឈាមរបស់អ្នក (ដែលគេហៅបន្ទុកមេរោគ) ឱ្យថិតនៅក្នុងកម្រិតមួយដ៏ទាបដែលតេស្តមិនអាចឃើញ



ប្រសិនបើបន្ទុកមេរោគអេដស៍នៅក្នុងឈាមរបស់អ្នក "មិនអាចរាប់បាន" ហើយអ្នករក្សាវាឱ្យនៅទាប "មិនអាចរាប់បាន" នេះតទៅ អ្នកនឹងគ្មានហានិភ័យក្នុងការចម្លងមេរោគអេដស៍ទៅដៃគូរួមភេទដែលពុំមានផ្ទុកមេរោគអេដស៍នោះឡើយ។

ប្រសិនបើអ្នកផ្ទុកមេរោគអេដស៍អ្នកគួរតែលេបថ្នាំព្យាបាលមេរោគអេដស៍ឱ្យបានឆាប់តាមដែលអាចធ្វើទៅបានដើម្បី៖



ពង្រឹងសុខភាពទូទៅរបស់អ្នក



បង្ការការចម្លងមេរោគអេដស៍ទៅអ្នកដទៃ



នៅពេលដែលអ្នកចាប់ផ្តើមលេបឱសថប្រឆាំងមេរោគអេដស៍ គឺអ្នកចាប់ផ្តើមដំណើររបស់អ្នកឆ្ពោះទៅរកបន្ទុកមេរោគអេដស៍ "មិនអាចរាប់បាន" របស់អ្នកហើយ។



ដោយការលេបថ្នាំរាល់ថ្ងៃទៅតាមវេជ្ជបញ្ជា អ្នកជំងឺភាគច្រើនអាច មានបន្ទុកមេរោគអេដស៍ "មិនអាចរាប់បាន" ក្នុងរយៈពេលរង្វង់ ៦ខែ។



បើអ្នកមានបន្ទុកមេរោគអេដស៍ "មិនអាចរាប់បាន" កាន់តែយូរ នោះអ្នកប្រហែលជានឹងនៅតែអាចធ្វើឱ្យបន្ទុកមេរោគអេដស៍ "មិនអាចរាប់បាន" តទៅទៀត។



ប៉ុន្តែមិនមែនគ្រប់គ្នាដែលលេបឱសថប្រឆាំងមេរោគអេដស៍ សុទ្ធតែអាចទទួលបានបន្ទុកមេរោគអេដស៍ "មិនអាចរាប់បាន" បានទេ។



វិធីតែមួយគត់ដើម្បីដឹងថាអ្នកមានបន្ទុកមេរោគអេដស៍ "មិនអាចរាប់បាន" គឺទៅពិនិត្យនិងជួបគ្រូពេទ្យរបស់អ្នកទៀងទាត់។

វិធីដែលប្រសើរបំផុតក្នុងការរក្សាខ្លួនអ្នកឱ្យនៅតែមានបន្ទុកមេរោគអេដស៍ “មិនអាចរាប់បាន” និងមានសុខភាពល្អ៖



លេបថ្នាំរាល់ថ្ងៃ តាមវេជ្ជបញ្ជា



ទៅជួបគ្រូពេទ្យទៀងទាត់



ការដែលមានបន្ទុកមេរោគអេដស៍ “មិនអាចរាប់បាន” និង រក្សាមេរោគឱ្យនៅក្នុងភាព “មិនអាចរាប់បាន” យូរអង្វែង បិតថេរ អ្នកនឹងអាចបង្ការ ការចម្លងមេរោគអេដស៍ ក្នុងពេលរួមភេទ ប៉ុន្តែមានហេតុផលផ្សេងៗទៀតដែលអ្នកនិងដៃគូរបស់អ្នកអាចពិចារណា បន្ថែមវិធានការបង្ការផ្សេងទៀតដូចជា ស្រោមអនាម័យ និង ប្រិព (PrEP)

ពិបាកក្នុងការរក្សាមេរោគឱ្យនៅបិតក្នុងភាព “មិនអាចរាប់បាន”

ខកខានលេបថ្នាំ តាំងពីបានធ្វើតេស្តរាប់បន្ទុកមេរោគចុងក្រោយ

ការពារការឆ្លងជំងឺកាមរោគផ្សេងៗទៀត ដូចជា ស្វាយនិងប្រមេះ

អ្នកឬក៏ដៃគូរបស់អ្នកចង់បានបន្ថែមអារម្មណ៍ស្ងប់ស្ងាត់ឥតកង្វល់



ដើម្បីជួយអ្នកឱ្យបិតនៅក្នុងដំណើររបស់អ្នក ជាការសំខាន់ដែលអ្នកត្រូវមានអ្នកផ្តល់សេវាម្នាក់ដែលអ្នកមានអារម្មណ៍សុខស្រួលជាមួយ និងទទួលបានការគាំទ្រពីគាត់។ ការនេះក៏គិតផងដែរដល់តម្រូវការការព្យាបាលផ្សេងទៀត។




ទោះអ្នកជានរណាក៏ដោយ ដែលបិតនៅលើការធ្វើដំណើរឆ្ពោះទៅរកបន្ទុកមេរោគអេដស៍ “មិនអាចរាប់បាន” នេះ ការបិតនៅជាប់នឹងការព្យាបាល នឹងជួយធ្វើឱ្យសុខភាពរបស់អ្នកប្រសើរឡើង ។



# “គ្មានការចម្លងមេរោគអេដស៍”





ដៃគូសហការ

PEPFAR USAID EpiC UNAIDS

CLINTON HEALTH ACCESS INITIATIVE magna AHF CPN+

WHO US_CDC CRS